សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ យើងសូមថ្កោលទោសកងកម្លាំងប្រដាប់អាវុធ ស្រុកឱដ្ដុង្គខេត្តកំពង់ស្ពឺ ដែលបាញ់ពលរដ្ឋខ្មែរត្រូវរបួសជាង១០នាក់ ។

Website: www.hoksavann.org

ថ្ងៃទី២២ មីនា ២០១០



នៅព្រឹកថ្ងៃព្រហស្បត្តិ៍១៨មីនា២០១០ កងកម្លាំងប្រដាប់អាវុធដែលចុះអនុវត្តសាលដីការបស់តុលាការខេត្តកំពង់ស្ពឺ ក្នុងការរឹបអូសយកដីនៅភូមិស្កុកស្លា ឃុំភ្នំតូច ស្រុកឧដ្ដុង្គ ខេត្តកំពង់ស្ពឺបានប្រព្រឹត្តអំពើហឹង្សាបាញ់ប្រហារប្រជាពលរដ្ឋដោយកាំភ្លើង AK-47 ជាច្រើនគ្រាប់ បណ្តាលឲ្យប្រជាពលរដ្ឋត្រូវរងរបួសជាង១០នាក់ ។ មន្ត្រីនគរបាលបានដោះសារថា ប្រជាពលរដ្ឋបានផ្តើមអំពើហឹង្សាមុន សមត្ថកិច្ចក៏តបតដើម្បីដោះខ្លួន ។ តំណាងប្រជាពលរដ្ឋដែលធ្វើការតវ៉ាបានថ្លែងថា ភាគីប្រជាពលរដ្ឋមានបំណងសុំចរចារកដំណោះស្រាយដោយសន្តិវិធី តែកងកម្លាំងប្រដាប់អាវុធពុំព្រមស្តាប់ ហើយគំរាមកំហែងប្រជាពលរដ្ឋរហូតដល់មានការប៉ះទង្គិចគ្នា សមត្ថកិច្ចក៏បាញ់ទៅលើប្រជាពលរដ្ឋតែម្តងទៅ ។ តាមពត៌មានថា ដីនោះមានទំហំ៦៥ហិកតា កាន់កាប់ដោយពលរដ្ឋខ្មែរចំនួន៨៨គ្រួសារ តាំងពីឆ្នាំ១៩៨០ បានសម្បទានទៅឲ្យក្រុមហ៊ុនតៃវ៉ាន់ ដែលមានខ្មែរអ្នកមានបុណ្យស័ក្តិម្នាក់ចូលហ៊ុនផង ។ គេតែងនិយាយថា ប្រជាពលរដ្ឋក្តីពុំងាយឈ្នះក្រុមហ៊ុននិងអ្នកមានបុណ្យស័ក្តិទេ ព្រោះពុំមានដុល្លារសូកប៉ាន់តុលាការ ។

ពេលនេះ យើងពុំវែកញែកអំពីខាងណាប្រើហឹង្សាមុននិងក្រោយទេ ហើយក៏មិនវែកញែកថា តើការកាត់ក្តីនោះមានយុត្តិធម៌ ឬមិនមានយុត្តិធម៌ទេ យើងវែកញែកតែចំពោះនគរបាលប្រើកាំភ្លើងបាញ់ទៅលើប្រជាពលរដ្ឋដែលគ្មានអាវុធក្នុងដៃ ។ ប្រជាពលរដ្ឋពុំមែនជាអ្នកប្រព្រឹត្តអំពើចោរកម្ម គ្មានគ្រឿងអាវុធក្នុងដៃ ហេតុអ្វីបានជាមន្ត្រីនគរបាលដែលមានគ្នាជាង៦០នាក់ មកបង្ក្រាបប្រជាពលរដ្ឋដោយកាន់អាវុធគ្រប់ដៃផង ។ តាមប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យនិងគោរពសិទ្ធិមនុស្ស នគរបាលដែលចុះទៅការពារប្រជាពលរដ្ឋ ឬបង្ក្រាបប្រជាពលរដ្ឋ គេប្រើខែលនិងរបាំងមុខ ខ្លាចប្រជាពលរដ្ឋចោលដុំថ្ម ដើម្បីទប់កុំឲ្យត្រូវដល់មុខ និងត្រូវដល់ខ្លួន គេមិនកាន់កាំភ្លើងឡើយ ។ បើប្រជាពលរដ្ឋធ្វើកូដកម្មឬបាតុកម្មដោយសន្តិវិធី នគរបាលត្រូវតែរក្សាសន្តិសុខជូនប្រជាពលរដ្ឋ ។ នគរបាលអាចចាត់វិធានការរាំងរា ឬឃាត់ឃាំងចំពោះបាតុករដែលប្រើហឹង្សាដោយបាញ់ទឹកបំបែក ហើយគេកម្រប្រើដំបងឆក់ណាស់ ព្រោះដំបងឆក់នាំឲ្យប្រជាពលរដ្ឋមានរបួស និងខូចសតិស្មារតី ។ វិធានការណាដែលធ្វើឲ្យប្រជាពលរដ្ឋមានទុក្ខតាមផ្លូវកាយ គេតែងតែជៀសវាង បើបៀតបៀនប្រជាពលរដ្ឋឈ្មោះថាជាអ្នករំលោភសិទ្ធិមនុស្ស ត្រូវឡើងតុលាការកាត់ទោស ។

នេះពុំមែនជាលើកទីមួយទេ ដែលមន្ត្រីសន្តិសុខបានបាញ់ប្រជាពលរដ្ឋ ពីរបីឆ្នាំមុនក៏ធ្លាប់បានបាញ់ប្រជាពលរដ្ឋនៅស្រុកអូរជ្រៅ ខេត្តបាត់ដំបង បានស្លាប់និងមានរបួសជាច្រើននាក់ ដោយសារប្រជាពលរដ្ឋការពារដីរបស់ខ្លួន ហើយអ្នកបាញ់នោះបានរួចខ្លួន ។ តាមរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្នចែងថា រាជាណាចក្រខ្មែរកាន់របបប្រជាធិបតេយ្យសេរីពហុបក្ស ។ យើងឆ្ងល់ថា មន្ត្រីសន្តិសុខដែលមានភារកិច្ចរក្សាសន្តិសុខជូនប្រជាពលរដ្ឋតាមរបបប្រជាធិបតេយ្យ ហេតុអ្វីបានមន្ត្រីស្រុកខ្មែរនេះចេះតែតាមធ្វើបាបប្រជាពលរដ្ឋ រហូតប្រើកាំភ្លើងបាញ់ប្រជាពលរដ្ឋបែបនេះ ឬមកពីមិនបានរៀនសូត្រចេះដឹងអំពីមុខងាររបស់ខ្លួន ឬមកពីបំរើក្រុមហ៊ុននិងអ្នកមានបុណ្យស័ក្តិដែលសំបូរដុល្លារ ? ។

ខ្មែរគ្រប់រូបមានបំណងដូចគ្នា គឺចង់ឲ្យប្រទេសរបស់ខ្លួនបានចំរើនលូតលាស់ ដូចជាការធ្វើវិនិយោគទុន ទំនងជាប្រជាពលរដ្ឋពុំជំទាស់ទេ ប៉ុន្តែការធ្វើសម្បទានដីទៅឲ្យក្រុមហ៊ុន ដែលប៉ះពាល់ដល់ដីប្រជាពលរដ្ឋ ត្រូវដោះស្រាយឲ្យមានតម្លាភាពប្រកបដោយយុត្តិធម៌ ។ បានសេចក្តីថា ត្រូវសងសំណាងឲ្យសមរម្យតាមទីផ្សារ ។ មួយទៀត បើដីនោះជាដីរបស់រដ្ឋ ប៉ុន្តែប្រជាពលរដ្ឋបានរស់នៅជាយូរហើយ ត្រូវរកដីជូនប្រជាពលរដ្ឋ ។ បើខូចខាតផ្ទះរបស់ប្រជាពលរដ្ឋ ត្រូវសង់ផ្ទះជូនប្រជាពលរដ្ឋ មុននឹងឲ្យប្រជាពលរដ្ឋចាកចេញពីដីធ្វើសម្បទាននោះ ឲ្យស្របតាមពាក្យរបស់អ្នកដឹកនាំរាជរដ្ឋាភិបាលតែងពោលថា មិនឲ្យប្រជាពលរដ្ឋអត់បាយអត់ទីលំនៅឡើយ ។ ចុះឥឡូវនេះ ប្រជាពលរដ្ឋនៅស្រុកឧដ្ដុង្គ ខេត្តកំពង់ស្ពឺ ត្រូវនគរបាលចុះមកដេញចេញពីលំនៅរបស់ខ្លួន រុះរើផ្ទះអស់ តើប្រជាពលរដ្ឋទៅរស់នៅទីណា ? បើតុលាការសំរេចសាលក្រមបែបនេះ តើមានគិតពីជីវិតប្រជាពលរដ្ឋឬទេ ? នៅប្រទេសកាន់របបប្រជាធិបតេយ្យ គេគិតអំពីវាសនានៃប្រជាពលរដ្ឋខ្លាំងណាស់ បើអត់ការធ្វើ គេផ្តល់ជំនួយសង្គមកិច្ចឬជំនួយមនុស្សធម៌ ដើម្បីបន្តដំណើរជីវិត គេផ្តល់ប្រាក់ចូលនិវត្តន៍គ្រប់គ្នាសំរាប់មនុស្សចាស់ធ្វើការមិនកើត ។ បើអាជ្ញាធរខ្មែរដេញប្រជាពលរដ្ឋ ដែលមិនបានដោះស្រាយឲ្យទៅរស់នៅទីណាទេ ទុកជាសម្លាប់ប្រជាពលរដ្ឋឬទេ ? បើមិនចេញអញបាញ់ ទុកប្រជាពលរដ្ឋខ្មែរដូចជាសត្វតិរច្ឆាន ។

តើអំពើឧក្រិដ្ឋនេះចេញពីថ្នាក់លើ គឺរាជរដ្ឋាភិបាលរបស់បក្សប្រជាជន ឬជាគំនិតថ្នាក់ក្រោមទេ បើវិធានការនេះចេញពីថ្នាក់ក្រោមទេ សូមរាជរដ្ឋាភិបាលចេញសារាចរមួយជាបន្ទាន់ដល់ថ្នាក់ក្រោម ដោយដោះស្រាយយ៉ាងណាឲ្យប្រជាពលរដ្ឋរស់ផង ហើយសូមមន្ត្រីសន្តិសុខកុំកាន់អាវុធក្នុងដៃពេលចុះទៅជួបប្រជាពលរដ្ឋ ។៚